ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ៧៣០៧ MIH / 2014

# ញត្តិគាំទ្រ
## សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

យើងខ្ញុំជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម សូមសម្តែងនូវការសោកស្តាយយ៉ាងខ្លាំង និងសូមធ្វើការថ្កោលទោសយ៉ាងដាច់អហង្ការចំពោះឯកឧត្តម សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិ ដែលបានធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ **អង្គព្រះមហាក្សត្រ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត តាមរយៈលិខិតរបស់ខ្លួនចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ២០១៤ តបទៅនឹងព្រះរាជសារបើកបវេសនកាលនៃរដ្ឋសភានាសម័យប្រជុំលើកទី២ នីតិកាលទី៥ កាលពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤ កន្លងទៅនេះ។

យើងខ្ញុំទាំងអស់គ្នា ពិតជាមិនអាចទទួលយកបានជាដាច់ខាត ចំពោះទង្វើអគតិរបស់ឯកឧត្តម សម រង្ស៊ី ដែលបានបង្ហាញឱ្យឃើញយ៉ាងច្បាស់នូវការរំលោភ ប្រមាថមាក់ងាយដល់ព្រះកិត្តិយស ព្រះកិត្តិនាមរបស់ **អង្គព្រះមហាក្សត្រ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតរបស់ប្រជាជាតិ និងប្រជាពលរដ្ឋខ្មែរ ដូចមានចែងក្នុងមាត្រា៧ និងមាត្រា៨ នៃ រដ្ឋធម្មនុញ្ញថា **«អង្គព្រះមហាក្សត្រមិនអាចនរណារំលោភបំពានបានឡើយ»** និង **«អង្គព្រះមហាក្សត្រទ្រង់គង់ជានិមិត្តរូបនៃឯកភាពជាតិ និរន្តរភាពជាតិ ជាអ្នកធានាឯករាជ្យជាតិ អធិបតេយ្យ បូរណភាពទឹកដី និងជាអ្នកធានានូវការគោរពសិទ្ធិមនុស្ស និងសេរីភាពរបស់ប្រជាពលរដ្ឋគ្រប់រូប»**។

មិនតែប៉ុណ្ណោះឯកឧត្តម សម រង្ស៊ី នៅបានញុះញង់ និងជំរុញឲ្យព្រះមហាក្សត្រអនុវត្តផ្ទុយពីរដ្ឋធម្មនុញ្ញ ដែលទង្វើនេះ មានតម្លៃស្មើនឹងការធ្វើរដ្ឋប្រហាររដ្ឋធម្មនុញ្ញ ហើយជាពិសេសប្រមាថមាក់ងាយ និងប្រឆាំងយ៉ាងជាក់ស្តែងដែលមិនអាចប្រកែកបានទៅលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០០៣ ដែលបានសម្រេចថា ចំនួនសមាជិកសភា ១២០រូប មិនពាក់ព័ន្ធទៅនឹងការបើកសម័យប្រជុំសភាលើកដំបូង ក្រោមព្រះរាជាធិបតីភាពរបស់ព្រះមហាក្សត្រនោះទេ។ ម្យ៉ាងវិញទៀត ដំណើរការរបស់រដ្ឋសភា គឺបានធ្វើឡើងស្របតាមមាត្រា៨២ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា៥ថ្មី(ពីរ) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ដែលត្រូវការតែចំនួនកូរ៉ុមលើសពីពាក់កណ្តាល ពោលគឺ ៥០ភាគរយបូក១ នៃចំនួនសមាជិករដ្ឋសភាទាំងមូលតែប៉ុណ្ណោះ ក្នុងការធ្វើការអនុម័តលើបញ្ហាទាំងឡាយណាដែលទាមទារសម្លេងភាគច្រើនដាច់ខាត (៥០ភាគរយបូក១) នៃចំនួនសមាជិករដ្ឋសភាទាំងមូល ដោយគោរពតាមកូរ៉ុមដូចមានចែងក្នុងមាត្រា៨៨ថ្មី(ពីរ)នៃរដ្ឋធម្មនុញ្ញ ដែលរួមមានទាំងការបង្កើតរាជរដ្ឋាភិបាលផង។

ការយាងបើកសម័យប្រជុំរដ្ឋសភាលើកដំបូងនីតិកាលទី៥ កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣ និងការផ្ញើព្រះរាជសាររបស់ ព្រះករុណាព្រះមហាក្សត្រ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតនៃយើង គឺជាការឆ្លុះបញ្ចាំងនូវព្រះរាជតួនាទី និងព្រះរាជគោលបំណងដ៏ខ្ពង់ខ្ពស់បំផុត ដើម្បីរក្សាសន្តិសុខ សន្តិភាព និងស្ថិរភាពនយោបាយ និង



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥ ២៣ ២១១ ៧៧៥

ដើម្បីជានាការប្រព្រឹត្តទៅនៃអំណាចសាធារណៈឲ្យមានភាពទៀងទាត់ ដែលជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍជាតិ ដូចមានចែងក្នុងមាត្រា៩ នៃរដ្ឋធម្មនុញ្ញ។

ដូចនេះ ទង្វើដ៏គឃ្លើនរបស់ឯកឧត្តម សម រង្ស៊ី បានបញ្ជាក់ឱ្យសាធារណៈមតិជាតិ និងអន្តរជាតិឃើញកាន់តែច្បាស់ថា ឯកឧត្តម សម រង្ស៊ី បានបំពានដល់ស្ថាប័នកំពូលរបស់ជាតិ ព្រះរាជបល្ល័ង្ក និងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ដែលជារដ្ឋសភាកើតចេញពីឆន្ទៈរបស់ប្រជាពលរដ្ឋ តាមរយៈការបោះឆ្នោតជាសាកលត្រឹមត្រូវ សេរី និងយុត្តិធម៌។

យើងខ្ញុំទាំងអស់គ្នា សូមគាំទ្រយ៉ាងពេញទំហឹងចំពោះទស្សនៈ គោលជំហរ និងសេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០៥ ខែមេសា ឆ្នាំ២០១៤ ក្នុងទិសដៅធានាការកសាង អភិវឌ្ឍសង្គមជាតិ ការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ ដោយឈរលើមូលដ្ឋានគ្រឹះនៃការពង្រឹង និងការអនុវត្តនូវគោលការណ៍នីតិរដ្ឋ។ យើងខ្ញុំទាំងអស់គ្នាចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជានៅគ្រប់កាលៈទេសៈ និងការពារដាច់ខាតរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ហើយសូមគាំទ្រយ៉ាងម៉ឺងម៉ាត់រាល់ការចាត់វិធានការទាំងឡាយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងបុព្វហេតុការពារបាវចនា ជាតិ សាសនា ព្រះមហាក្សត្រ សេចក្តីថ្លៃថ្នូររបស់សង្គមជាតិ និងភាពសុខសាន្តរបស់ប្រជាជនយើង។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ២០១៤
**តំណាងថ្នាក់ដឹកនាំ មន្ត្រីរាជការក្រសួងឧស្សាហកម្ម និងសិប្បកម្ម**